លេខ ១ ចេញផ្សាយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១

# ព្រឹត្តបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២១

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

**មាតិកា**


- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១ ទំព័រ ១
- កិច្ចប្រជុំផ្លាស់ប្តូរនិងដកស្រង់បទពិសោធន៍ពាក់ព័ន្ធបរធនបាលកិច្ច ទំព័រ ១
- កិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិភាក្សាពីវឌ្ឍនភាព និងសមិទ្ធកម្មការងារ ទំព័រ ២
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២ ទំព័រ ២




រូបភាពក្នុងកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន។**

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១

នាព្រឹកថ្ងៃពុធ ១៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **អ.ស.ហ.**។

ក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សា **អ.ស.ហ.** បានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ដែលរួមមានទាំង **ន.ប.ធ.** ផងដែរ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំផ្លាស់ប្តូរ និងដកស្រង់បទពិសោធន៍ ពាក់ព័ន្ធបរធនបាលកិច្ច

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំមន្ត្រីនៃ **ន.ប.ធ.** ចូលរួមកិច្ចប្រជុំផ្លាស់ប្តូរ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធបរធនបាលកិច្ចជាមួយលោកបណ្ឌិត James Chang ស្ថាបនិកក្រុមហ៊ុន The First China Investment និង Trust Investment Committee of NKUST Affair Funds ព្រមទាំងក្រុមការងារ។ កម្មវិធីនេះបានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កា។



រូបភាពក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដាវ៉ា**។

## កិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិភាក្សាពីវឌ្ឍនភាព និងសមិទ្ធកម្មការងារ

នារសៀលថ្ងៃព្រហស្បតិ៍ ៨កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិភាក្សាពីវឌ្ឍនភាព និងសមិទ្ធកម្មការងារឆ្នាំ២០២១ និងទិសដៅការងារត្រូវអនុវត្ត ក្នុងឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់ ក៏ដូចជាគម្រោងអភិវឌ្ឍស្ថាប័ន អភិវឌ្ឍបទប្បញ្ញត្តិគ្រប់គ្រងពាក់ព័ន្ធ ព្រមទាំងអភិវឌ្ឍ និងកសាងធនធានមនុស្សនៅក្នុងក្របខណ្ឌនៃ **ន.ប.ធ.** ទាំងមូល។



រូបភាពក្នុងកិច្ចប្រជុំផ្ទៃក្នុងតាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដាវ៉ា**។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២

នាព្រឹកថ្ងៃអង្គារ ១៣ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **អសហ**។ ក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សា **អ.ស.ហ.** បានពិនិត្យ និងពិភាក្សាលើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុន **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក.** និងការងារផ្សេងៗ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពក្នុងកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២ តាមប្រព័ន្ធ Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888